# សេចក្ដីជូនដំណឹង

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

កាលបរិច្ឆេទ ៖ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៦

ជូនចំពោះ ៖ ពួកអ្នកមានសិទ្ធិអំណាចទូទៅ, ពួកចិតសិបនាក់ប្រចាំតំបន់, ប្រធានស្តេក, ប្រធានបេសកកម្ម និង ប្រធានមណ្ឌល, ប៊ីស្សព និង ប្រធានសាខា, សមាជិកនៃក្រុមប្រឹក្សាស្តេក និង ក្រុមប្រឹក្សាវួដ

មកពី ៖ ក្រុមប្រឹក្សាប្រតិបត្តិបព្វជិតភាព និង ក្រុមគ្រួសារ ( ៨០១-២៤០-២១៣៤ )

កម្មវត្ថុ ៖ ការងារបម្រើដល់មនុស្សដែលប្រតិព័ទ្ធភេទដូចគ្នា

---

ឥឡូវនេះ ធនធាននានាដែលបានធ្វើបច្ចុប្បន្នភាពទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា មានសម្រាប់បុគ្គលម្នាក់ៗ ក្រុមគ្រួសារ និង ក្រុមប្រឹក្សាវួដមានដូចខាងក្រោមនេះ ៖

- « ការប្រតិព័ទ្ធភេទដូចគ្នា » ដាក់ចូលនៅក្នុងប្រធានបទដំណឹងល្អ នៅលើ LDS.org ( សូមមើលឯកសារភ្ជាប់ )
- ការបង្រៀនរបស់សាសនាចក្រ ( សូមមើលឯកសារភ្ជាប់ )
- សំណួរដែលបានសួរជាញឹកញាប់ ( សូមមើលឯកសារភ្ជាប់ )
- គេហទំព័រ Mormonandgay.lds.org មានជាភាសាអង់គ្លេស
- ធនធានអំពីការងារបម្រើ (ministering.lds.org) មាន ១០ ភាសាសម្រាប់សមាជិកនៃក្រុមប្រឹក្សាវួដ និងក្រុមប្រឹក្សាស្តេក តាមរយៈធនធានអ្នកដឹកនាំ និងស្មៀននៅលើ LDS.org។

ធនធានទាំងនេះអាចនឹងត្រូវបានពិនិត្យមើលនៅក្នុងការប្រជុំក្រុមប្រឹក្សាស្តេក ឬវួដ ។

# ការប្រតិព័ទ្ធភេទដូចគ្នា

ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦

សាសនាចក្រនៃ
**ព្រះយេស៊ូវគ្រីស្ទ**
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

---

*ដកស្រង់ចេញមកពីប្រធានបទដំណឹងល្អនៅគេហទំព័រ topics.lds.org៖*

ការប្រតិព័ទ្ធភេទដូចគ្នាសំដៅទៅលើការប្រតិព័ទ្ធទៅលើមនុស្សម្នាក់ដែលមានភេទដូចគ្នាខាងសតិអារម្មណ៍ ខាងរូបកាយ ឬខាងផ្លូវភេទ ។ ការជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា គឺពុំដូចគ្នាទេចំពោះមនុស្សគ្រប់រូប ។ មនុស្សខ្លះអាចនឹងមានអារម្មណ៍ប្រតិព័ទ្ធយ៉ាងខ្លាំងទៅមនុស្សដែលមានភេទដូចគ្នា ខណៈដែលមនុស្សខ្លះទៀតអាចនឹងមានអារម្មណ៍ប្រតិព័ទ្ធទៅលើមនុស្សទាំងពីរភេទ ។

សាសនាចក្របង្ហាញពីលក្ខណៈខុសគ្នារវាងការប្រតិព័ទ្ធភេទដូចគ្នា និងឥរិយាបទនៃការរួមភេទដូចគ្នា ។ មនុស្សដែលមានការប្រតិព័ទ្ធភេទដូចគ្នា ឬត្រូវបានស្គាល់ថាជាមនុស្សខ្ទើយប្រុស មនុស្សខ្ទើយស្រី ឬមនុស្សខ្ទើយ អាចចុះ និងរក្សាសេចក្តីសញ្ញាជាមួយព្រះ ហើយចូលរួមក្នុងសាសនាចក្រដោយពេញលេញ និងដោយសក្តិសម ។ ការស្គាល់ថាជាមនុស្សខ្ទើយប្រុស មនុស្សខ្ទើយស្រី ឬមនុស្សខ្ទើយ ឬ មានការប្រតិព័ទ្ធភេទដូចគ្នា គឺពុំមែនជាអំពើបាបនោះទេ ហើយក៏មិនបានហាមប្រាមមិនឲ្យចូលរួមក្នុងសាសនាចក្រ មានការហៅបម្រើ ឬចូលរួមក្នុងព្រះវិហារបរិសុទ្ធនោះដែរ ។

ភាពបរិសុទ្ធខាងផ្លូវភេទ គឺជាផ្នែកដ៏សំខាន់មួយនៃផែនការរបស់ព្រះសម្រាប់សុភមង្គលរបស់យើង ។ ទំនាក់ទំនងខាងផ្លូវភេទ ត្រូវបានរក្សាសម្រាប់បុរសម្នាក់ និងស្ត្រីម្នាក់ដែលបានរៀបការ និងបានសន្យាថាមានភក្តីភាពចំពោះគ្នាទៅវិញទៅមកទាំងស្រុង ។ ទំនាក់ទំនងខាងផ្លូវភេទរវាងបុរសម្នាក់ និងស្ត្រីម្នាក់ដែលពុំបានរៀបការ ឬរវាងមនុស្សដែលមានភេទដូចគ្នា គឺល្មើសនឹងក្រឹត្យវិន័យដ៏សំខាន់បំផុតមួយរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើង ហើយវារាំងស្ទះដល់ការរីកចម្រើនដ៏អស់កល្បជានិច្ចរបស់យើង ។ មនុស្សដែលមានចេតនាខាងផ្លូវភេទណាមួយដែលល្មើសនឹងក្រឹត្យវិន័យនៃព្រហ្មចារីភាពអាចត្រូវបានផ្សះផ្សាជាមួយនឹងព្រះតាមរយៈការកែប្រែចិត្ត ។ ក្នុងនាមជាអ្នកដើរតាមព្រះគ្រីស្ទ យើងជំទាស់នឹងឥរិយាបទអសីលធម៌ ហើយព្យាយាមដើម្បីប្រែក្លាយដូចជាទ្រង់ ។ យើងស្វែងរកការណែនាំមកពីព្រះវិញ្ញាណបរិសុទ្ធ និងជំនួយមកពីព្រះអង្គសង្គ្រោះ ដែលស្គាល់របៀបជួយដល់យើង នៅពេលយើងត្រូវបានល្បួង ( សូមមើលកូរិនថូសទី ១ ១០:១៣,គ និង ស ៦២:១) ។ ប្រសិនបើយើងចុះចាញ់តាមការល្បួងខាងផ្លូវភេទ ហើយល្មើសនឹងច្បាប់ព្រហ្មចារីភាព នោះយើងអាចប្រែចិត្ត អាចត្រូវបានអភ័យទោស ហើយចូលរួមនៅក្នុងការរាប់អានពេញលេញក្នុងសាសនាចក្រ ។

យើងអាចនឹងមិនដឹងជាក់លាក់ថាហេតុអ្វីមនុស្សខ្លះមានអារម្មណ៍ប្រតិព័ទ្ធអ្នកដទៃដែលមានភេទដូចគ្នានោះទេ ប៉ុន្តែចំពោះមនុស្សខ្លះវាគឺជាភាពពិតដ៏ស្មុគស្មាញមួយ ហើយវាជាចំណែកនៃបទពិសោធន៍មនុស្សលោក ។ ព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ទ្រង់ញាណដឹងដ៏ឥតខ្ចោះអំពីឧបសគ្គទាំងអស់ដែលយើងជួបនៅលើផែនដីនេះ ហើយយើងអាចត្រឡប់ទៅរកទ្រង់សូមការលួងលោមចិត្ត អំណរ ក្តីសង្ឃឹម និងការដឹកនាំ ( សូមមើលអាលម៉ា ៧:១១-១២) ។ មិនថាយើងជួបនឹងឧបសគ្គអ្វីខ្លះក្នុងជីវិតនេះទេ យើងទាំងអស់គ្នាគឺជាកូនចៅរបស់ព្រះ ដែលសមនឹងទទួលយកនូវសន្តានចិត្តល្អ និងក្តីមេត្តាករុណាពីគ្នាទៅវិញទៅមក (រ៉ូម ៨:១៦-១៧) ។ នៅពេលយើងបង្កើតបរិយាកាសគាំទ្រគ្នា នោះយើងស្ថាបនាសេចក្តីសប្បុរស និងសេចក្តីអាណិតអាសូរដល់គ្នាទៅវិញទៅមក ហើយទទួលបានផលប្រយោជន៍មកពីទស្សនវិស័យ និងជំនឿរមគ្នារបស់យើង ។

# ការបង្រៀនរបស់សាសនាចក្រ

ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១៦

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

---

*ដកស្រង់ចេញមកពី mormonandgay.lds.org។*

### ព្រះទ្រង់ស្រឡាញ់កូនចៅរបស់ទ្រង់គ្រប់រូប

គ្មានអ្វីដែលបង្ហាញពីជម្រៅនៃសេចក្ដីស្រឡាញ់ និងការជួយរបស់ព្រះបានពេញលេញជាងព្រះឆន្ទៈដើម្បីលះបង់ព្រះរាជបុត្រារបស់ទ្រង់ដើម្បីឲ្យយើង ដែលជាកូនចៅរបស់ទ្រង់ អាចយកឈ្នះលើសេចក្ដីស្លាប់ ហើយទទួលបានជីវិតដ៏អស់កល្បជានិច្ចនោះទេ ។ « ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ » (យ៉ូហាន ៣:១៦) ។ គ្មានអ្វីដែលបង្ហាញពីសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទប្រសើរជាងព្រះឆន្ទៈលះបង់ព្រះជន្មរបស់ទ្រង់ធ្វើឲ្យធួននឹងអំពើបាបរបស់មនុស្សលោក បង់ថ្លៃសងរាល់ការរងទុក្ខ និងភាពអយុត្តិធម៌ ហើយផ្ដាច់ចំណងសេចក្ដីស្លាប់របស់មនុស្សទាំងអស់នោះទេ ( សូមមើលអាលម៉ា ៧:១១-១៣) ។ « គ្មានអ្នកណាមានសេចក្ដីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្ដូរជីវិត ជំនួសពួកសម្លាញ់របស់ខ្លួននោះទេ » (យ៉ូហាន ១៥:១៣) ។

នៅក្នុងសុន្ទរកថាសន្និសីទទូទៅខែតុលា ឆ្នាំ ២០០៩ ប្រធាន ឌៀថើរ អេហ្វ អុជដុហ្វ បានពិពណ៌នាអំពីសេចក្ដីស្រឡាញ់របស់ព្រះ ៖

« ព្រះមិនបានទតមើលមនុស្សតែសំបកក្រៅនោះទេ ។ ខ្ញុំជឿជាក់ថា ទ្រង់មិនខ្វល់ឡើយ ទោះជាយើងរស់នៅក្នុងវិមាន ឬខ្ទម ទោះជាយើងមានរូបរាងសង្ហា ឬមិនស្រស់ស្អាត ទោះបីជាយើងជាមនុស្សល្បីឈ្មោះ ឬគ្មានកេរ្ដិ៍ឈ្មោះក្ដី ។ ទោះជាយើងគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្ដី ក៏ព្រះស្រឡាញ់យើងអស់ពីព្រះទ័យទ្រង់ដែរ ។ ទោះជាយើងមិនបានល្អឥតខ្ចោះ ក៏ព្រះស្រឡាញ់យើងយ៉ាងល្អឥតខ្ចោះដែរ ។ ទោះជាយើងមានអារម្មណ៍ថាវង្វេងផ្លូវ ហើយគ្មានត្រីវិស័យនាំផ្លូវក្ដី ក៏សេចក្ដីស្រឡាញ់របស់ព្រះឱបក្រសោបយើងទាំងស្រុងដែរ ។

« ទ្រង់ស្រឡាញ់យើង ដោយសារតែទ្រង់ពោរពេញដោយទំហំនៃសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធ សុទ្ធសាធ និងពុំអាចពិពណ៌នាបានឡើយ ។ យើងសំខាន់ចំពោះព្រះពុំមែនដោយសារតែប្រវត្តិរូបរបស់យើងនោះទេ ប៉ុន្តែដោយសារតែយើងគឺជាកូនចៅរបស់ទ្រង់ ។ ទ្រង់ស្រឡាញ់យើងគ្រប់ៗគ្នា » ( « សេចក្ដីស្រឡាញ់របស់ព្រះ » សន្និសីទទូទៅ ខែតុលា ឆ្នាំ ២០០៩ ) ។

ព្រះស្រឡាញ់យើងទាំងអស់គ្នា ។ ទ្រង់ស្រឡាញ់ទាំងអ្នកដែលមានជំនឿផ្សេង និងអ្នកដែលគ្មានជំនឿ ។ ទ្រង់ស្រឡាញ់អ្នកដែលរងទុក្ខ ។ ទ្រង់ស្រឡាញ់អ្នកមាន ក៏ដូចជាអ្នកក្រីក្រ ។ ទ្រង់ស្រឡាញ់មនុស្សគ្រប់ជាតិសាសន៍ និងវប្បធម៌ ទាំងអ្នករៀបការរួច ឬនៅលីវ និងអ្នកដែលមានជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា ឬស្គាល់ថាជាមនុស្សខ្ទើយប្រុស មនុស្សខ្ទើយស្រី ឬមនុស្សខ្ទើយ ។ ហើយព្រះអម្ចាស់រំពឹងឲ្យយើងធ្វើតាមគំរូទ្រង់ ។

### យើងត្រូវបានបង្គាប់ឲ្យស្រឡាញ់ព្រះ និងស្រឡាញ់គ្នាទៅវិញទៅមក

« ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្តអស់ពីព្រលឹង ហើយអស់អំពីគំនិតឯង ។ នេះជាបញ្ញត្តិយ៉ាងសំខាន់ទី ១ ។ ហើយបញ្ញត្តិទី ២ ក៏បែបដូចគ្នាគឺថា « ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » (ម៉ាថាយ ២២:៣៧–៣៩) ។

« នេះជាសេចក្ដីបញ្ញត្តិរបស់ខ្ញុំ គឺឲ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ » ( យ៉ូហាន ១៥:១២ ) ។

យើងបង្ហាញសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះ តាមរយៈការរក្សាបទបញ្ញត្តិរបស់ទ្រង់ ( សូមមើល យ៉ូហាន ១៤:១៥) និងតាមរយៈការស្រឡាញ់គ្នាទៅវិញទៅមក ( សូមមើល យ៉ូហាន ១៣:៣៤) ។ ប្រសិនបើជាអ្នកមានសមាជិកគ្រួសារ ឬមិត្តម្នាក់ដែលជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា ឬស្គាល់ថាជាមនុស្សខ្ទើយ សូមស្រឡាញ់ពួកគេ ។ ប្រធាន ហិនរី ប៊ី អាវរិង បានសង្កេតឃើញថា

« ប្រសិនបើអ្នកចង់នៅជិតនឹងនរណាម្នាក់ដែលអ្នកស្រឡាញ់ ប៉ុន្តែជាអ្នកដែលនៅបែកពីអ្នក នោះអ្នកដឹងថាត្រូវធ្វើយ៉ាងណាហើយ ។ អ្នកនឹងរកវិធីមួយ ដើម្បីនិយាយនឹងពួកគេ អ្នកនឹងស្ដាប់ពួកគេ ហើយអ្នកនឹងរកឃើញដំណោះស្រាយធ្វើរឿងទាំងឡាយសម្រាប់គ្នាទៅវិញទៅមក ។ កាលណាវាកើតឡើង កាន់តែញឹកញាប់ ហើយបន្តទៅកាន់តែយូរ នោះចំណងនៃសេចក្ដីស្រឡាញ់នឹងមានកាន់តែជ្រាលជ្រៅ ។ ប្រសិនបើពេលវេលាជាច្រើនបានកន្លងផុតទៅ ដោយគ្មានការនិយាយ ការស្ដាប់ និងធ្វើអ្វីបន្តិចសោះនោះ នោះចំណងទំនាក់ទំនងនឹងត្រូវទន់ខ្សោយ ។ ព្រះគឺល្អឥតខ្ចោះ ព្រមទាំងមានគ្រប់ព្រះចេស្ដា ហើយអ្នក និងខ្ញុំ គឺជាមនុស្សរមែងស្លាប់ ។ ប៉ុន្តែទ្រង់គឺជាព្រះវរបិតារបស់យើង ទ្រង់ស្រឡាញ់យើង ហើយទ្រង់ប្រទានឱកាសដូចគ្នានេះ ដើម្បីឲ្យយើងខិតទៅកាន់តែជិតនឹងទ្រង់ ក៏ដូចជាមិត្តម្នាក់ដែរ ។ ហើយអ្នកនឹងធ្វើវាតាមរបៀបដែលស្រដៀងគ្នានេះដែរគឺ ៖ ការនិយាយ ការស្ដាប់ និងការធ្វើ » ( To Draw Closer to God » សន្និសីទទូទៅខែមេសា ឆ្នាំ ១៩៩១ ) ។

អ្នកបង្ហាញសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះតាមរយៈការស្រឡាញ់ និងការបម្រើដល់អ្នកដទៃ ។ ហើយមើលចុះ យើងសុំប្រាប់អ្នកនូវការណ៍ទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាអាចមានប្រាជ្ញា ដើម្បីឲ្យអ្នករាល់គ្នាអាចបានដឹងថា កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ (ម៉ូសាយ ២:១៧) ។

តើការស្រឡាញ់គ្នាទៅវិញទៅមកមានន័យយ៉ាងណា ? ប្រសិនបើស្រឡាញ់ ត្រូវតែចេះខ្វល់ខ្វាយ ។ ប្រសិនបើស្រឡាញ់ ត្រូវចេះស្ដាប់ ។ ប្រសិនបើស្រឡាញ់ ត្រូវចេះរាប់រកគ្នា ។ ប្រសិនបើស្រឡាញ់ត្រូវចេះបំផុសគំនិត ។ សេចក្ដីស្រឡាញ់គឺជាចំណុចខ្លឹមដែលយើងជាមនុស្ស ដ្បិតយើងជាកូនចៅរបស់ព្រះ ហើយ « ព្រះគឺជាសេចក្ដីស្រឡាញ់ » (យ៉ូហានទី ១ ៤:៨) ។ នៅពេលអាហារយប់ថ្ងៃចុងក្រោយ ព្រះអង្គសង្គ្រោះបានបង្រៀនថា « គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្ដីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមក » ( យ៉ូហាន ១៣:៣៥ ) ។

បញ្ញត្តិឲ្យស្រឡាញ់គ្នាទៅវិញទៅមករួមមានទាំងឲ្យស្រឡាញ់អ្នកទាំងឡាយណាដែលពុំយល់ឃើញអំពីពិភពលោកនេះ ដូចជាយើងយល់ឃើញ ។ ដូចដែលអែលឌើរ ដាល្លិន អេក អូក បានពន្យល់ថា ៖

« ក្នុងទំនាក់ទំនង និងកាលៈទេសៈជាច្រើនក្នុងជីវិត យើងត្រូវតែរស់នៅក្នុងភាពខុសគ្នា។ បើចាំបាច់ ភាពខុសគ្នារបស់យើងទាំងនេះ ពុំគួរបដិសេធ ឬបោះបង់ចោលនោះទេ ប៉ុន្តែក្នុងនាមជាសិស្សរបស់ព្រះគ្រីស្ទ យើងគួរតែរៀនរស់នៅដោយសុខសាន្តជាមួយអ្នកដទៃ ដែលគ្មានគុណតម្លៃ ឬទទួលយកការបង្រៀនដែលពួកគេបានមាន។ ផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតា ដែលយើងដឹងតាមរយៈវិវរណៈនៃការព្យាករ បានដាក់ឲ្យយើងស្ថិតនៅក្នុងស្ថានភាពជីវិតរមែងស្លាប់ ដែលយើងត្រូវរក្សាបទបញ្ញត្តិទាំងឡាយរបស់ទ្រង់។ វារួមមានទាំងការស្រឡាញ់អ្នកជិតខាងខ្លួនដែលមានវប្បធម៌ និងជំនឿខុសគ្នា ដូចទ្រង់ស្រឡាញ់យើង។ ដូចជាព្យាការីក្នុងព្រះគម្ពីរមរមនម្នាក់បានបង្រៀនថា យើងត្រូវតែឆ្ពោះទៅមុខដោយមាន ‹ សេចក្ដីស្រឡាញ់របស់ព្រះ និងមនុស្សទាំងអស់ › (នីហ្វៃទី ២ ៣១:២០) » ( « ការស្រឡាញ់អ្នកដទៃ និង ការរស់នៅជាមួយមនុស្សដែលមានភាពខុសគ្នា » សន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៤ ។

សេចក្ដីស្រឡាញ់របស់ព្រះ ពុំមែនជាលេសដោះសារអំពើបាបនោះទេ —« ដ្បិតយើងជាព្រះអម្ចាស់ ពុំអាចទតមើលអំពើបាប សូម្បីតែបន្តិចបន្តួចបានឡើយ »—ប៉ុន្តែគឺមានសេចក្ដីអន្ទះសារចង់អភ័យទោសឲ្យ— « ប៉ុន្តែអ្នកណាដែលប្រែចិត្ត ហើយធ្វើតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នោះនឹងបានអត់ទោស » ( គ . និង ស . ១:៣១–៣២) ។ ដូចគ្នានេះដែរ យើងពុំគួរបន្ទាបបទដ្ឋានក្នុងការរស់នៅ និងការការពារបទបញ្ញត្តិរបស់ព្រះនោះទេ ប៉ុន្តែដើម្បីឆ្លុះមើលឃើញឲ្យពេញលេញនូវសេចក្ដីស្រឡាញ់របស់ព្រះ នោះយើងត្រូវតែស្រឡាញ់គ្នាទៅវិញទៅមកដោយបើកចំហ និងទាំងស្រុង ដើម្បីកុំឲ្យមាននរណាម្នាក់អាចមានអារម្មណ៍ថាត្រូវគេបោះបង់ចោល ឬឯកោ ឬគ្មានក្ដីសង្ឃឹមឡើយ ។

**ព្រះអង្គសង្គ្រោះមានការយល់ដឹងដ៏ឥតខ្ចោះអំពីការលំបាកទាំងអស់របស់យើង**

« ដ្បិតឥឡូវនេះ យើងមើលឃើញបែបស្រអាប់ដូចជាដោយសារកញ្ចក់ តែនៅវេលានោះ នឹងឃើញមុខទល់នឹងមុខ ឥឡូវនេះខ្ញុំស្គាល់មិនទាន់អស់ តែនៅវេលានោះ ខ្ញុំនឹងស្គាល់វិញ ដូចជាព្រះទ្រង់ស្គាល់ខ្ញុំដែរ » (កូរិនថូសទី ១ ១៣:១២) ។

ក្នុងនាមជាមនុស្សរមែងស្លាប់ ការយល់ដឹងរបស់យើងគឺមានកំណត់ ។ យើងអាចប្រកាសជាមួយនីហ្វៃថា យើង « ដឹងថាព្រះអង្គទ្រង់ស្រឡាញ់កូនចៅរបស់ទ្រង់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំ មិនយល់ន័យនៃរឿងទាំងអស់នោះទេ » ( នីហ្វៃទី ១ ១១:១៧) ។

នៅពេលយើងស្វែងរកចម្លើយ និងការដឹកនាំក្នុងការធ្វើដំណើរផ្ទាល់ខ្លួនរបស់យើង នោះយើងអាចទុកចិត្តព្រះ និងទុកចិត្តលើព្រះចេស្ដានៅក្នុងការពលិកម្មធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ នៅពេលព្រះយេស៊ូវគ្រីស្ទលើកដាក់មកលើព្រះអង្គទ្រង់នូវអំពើបាបនៃពិភពលោក ទ្រង់ក៏បានភ្លក់គ្រប់ការឈឺចាប់ និងការរងទុក្ខដែលមនុស្សលោកគ្រប់រូបអាចមាន ៖

« ហើយព្រះយេស៊ូវគ្រីស្ទនឹងយាងទៅដោយរងការឈឺចាប់ និងទុក្ខវេទនា និងការល្បួងគ្រប់បែបយ៉ាងហើយទ្រង់ធ្វើយ៉ាងនេះ គឺដើម្បីឲ្យបានបំពេញនូវពាក្យទាំងឡាយ ដែលបានថែងមកថា ទ្រង់នឹងលើកដាក់លើខ្លួនទ្រង់នូវការឈឺចាប់ និងជំងឺទាំងឡាយរបស់រាស្ត្រទ្រង់ » (អាលម៉ា ៧:១១) ។

**អារម្មណ៍នៃការប្រតិព័ទ្ធភេទដូចគ្នា ពុំមែនជាអំពើបាបទេ ហើយយើងអាចជ្រើសរើសរបៀបដើម្បីឆ្លើយតបនឹងវា**

សាសនាចក្រពុំជំទាស់នឹងបុព្វហេតុនៃការប្រតិព័ទ្ធភេទដូចគ្នានោះទេ ។ នៅក្នុងឆ្នាំ ២០០៦ អែលឌើរ ដាល្លិន អេក អូក បានថ្លែងថា ៖

« សាសនាចក្រពុំជំទាស់នឹងបុព្វហេតុនៃការរងឥទ្ធិពល ឬទំនោរពីធម្មជាតិទាំងនេះ រួមមានទាំងអស់អ្នកដែលជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នានោះទេ » ( ការសម្ភាសជាមួយអែលឌើរ ដាល្លិន អេក អូក និងអែលឌើរ លែន ប៊ី វីកមែន ៖ « ការប្រតិព័ទ្ធភេទដូចគ្នា » ក្នុងឆ្នាំ ២០០៦ ) ។

អារម្មណ៍នៃការប្រតិព័ទ្ធភេទដូចគ្នាពុំមែនជាអំពើបាបទេ ។ អែលឌើរ អិម រ័សុល បាឡឺដ បានថ្លែងថា ៖

« ចូរយើងដឹងឲ្យបានច្បាស់ថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជឿថា ‹ ការជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នាគឺជាភាពពិតដ៏ស្មុគស្មាញមួយចំពោះមនុស្សជាច្រើន › ។ ការប្រតិព័ទ្ធតែម្យ៉ាងគឺពុំមែនជាអំពើបាបទេ ប៉ុន្តែការមានសកម្មភាពគឺជាអំពើបាប ។ ទោះជាបុគ្គលម្នាក់ៗពុំជ្រើសរើសមានការប្រតិព័ទ្ធប្រភេទនេះក្តី ក៏ពួកគេអាចជ្រើសរើសរបៀបដើម្បីឆ្លើយតបវាបានដែរ ។ សាសនាចក្រឈោងទៅជួយកូនចៅរបស់ព្រះទាំងអស់ដោយសេចក្តីស្រឡាញ់ និងការយល់ចិត្តរួមទាំង [ អ្នកទាំងឡាយដែលមានការប្រតិព័ទ្ធភេទដូចគ្នា ] › » ( « The Lord Needs You Now! »*Ensign* ខែកញ្ញា ឆ្នាំ ២០១៥ ទំព័រ ២៩ ) ។

ខណៈដែលការប្រតិព័ទ្ធភេទដូចគ្នាគឺពុំមែនជាអំពើបាបក្តី តែវាអាចជាឧបសគ្គមួយ ។ ខណៈដែលមនុស្សម្នាក់ប្រហែលជាមិនបានជ្រើសរើសដើម្បីមានអារម្មណ៍ទាំងនេះក្តី តែគាត់ ឬនាង អាចតាំងចិត្តដើម្បីរក្សាបទបញ្ញត្តិទាំងឡាយរបស់ព្រះ ។ ឪពុកម្តាយនៃកូនដែលមានជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា ឬស្គាល់ថាជាមនុស្សខ្ទើយ គួរតែជ្រើសរើសដើម្បីស្រឡាញ់ ហើយឱបក្រសោបកូនម្នាក់នោះ ។ ក្នុងនាមជាសហគមន៍នៃសមាជិកសាសនាចក្រនោះយើងគួរតែជ្រើសរើសបង្កើតជាសហគមន៍មួយដែលមានការស្វាគមន៍ ។

« ហើយទ្រង់អញ្ជើញយើងទាំងអស់គ្នាឲ្យមករកទ្រង់ ហើយទទួលទាននូវសេចក្តីល្អសប្បុរសរបស់ទ្រង់ ហើយទ្រង់ពុំបដិសេធអ្នកណាម្នាក់ ដែលមករកទ្រង់ឡើយ. . . មនុស្សទាំងអស់ដូចគ្នានៅចំពោះព្រះ » (នីហ្វៃទី ២ ២៦:៣៣) ។

**មនុស្សដែលរស់នៅតាមក្រឹត្យវិន័យរបស់ព្រះ អាចចូលរួមនៅក្នុងសាសនាចក្រដោយពេញលេញ**

« ប្រាកដមែន ខ្ញុំយល់ឃើញថា ព្រះមិនរើសមុខអ្នកណាទេ » (កិច្ចការ ១០:៣៤) ។

ព្រះសន្យាថា ប្រសិនបើយើងគោរពតាមក្រឹត្យវិន័យរបស់ទ្រង់ នោះយើងនឹងមានអំណរដ៏អស់កល្បជានិច្ច ហើយទ្រង់នឹងរក្សាការសន្យារបស់ទ្រង់ជានិច្ច ។ ច្បាស់ណាស់ មនុស្សដែលមានជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា ឬស្គាល់ថាជាមនុស្សខ្ទើយ អាចធ្វើ និងរក្សាការសន្យាទាំងឡាយចំពោះព្រះ ។ ពួកគេអាចដើរនៅក្នុងពន្លឺរបស់ទ្រង់ ។ ពួកគេអាចចូលរួមនៅក្នុងសាសនាចក្រដោយពេញលេញ ។

« បើសិនជាសមាជិកមានអារម្មណ៍ស្រឡាញ់មនុស្សភេទដូចគ្នា ប៉ុន្តែមិនជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តរួមភេទដូចគ្នាណាមួយទេ នោះពួកអ្នកដឹកនាំគួរតែគាំទ្រ និងលើកទឹកចិត្តពួកគេនៅក្នុងការតាំងចិត្តពួកគេឲ្យរស់នៅតាមច្បាប់ព្រហ្មចារីយភាព និងដើម្បីគ្រប់គ្រងគំនិតមិនសុចរិតនោះ ។ សមាជិកទាំងនេះអាចទទួលបានការហៅឲ្យបម្រើក្នុងសាសនាចក្រ ។ បើសិនជាពួកគេមានភាពសក្តិសម ហើយមានគុណសម្បត្តិគ្រប់គ្រាន់តាមរបៀបផ្សេងៗទៀត នោះពួកគេអាចកាន់ប័ណ្ណចូលព្រះវិហារបរិសុទ្ធ និងទទួលពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធបានផងដែរ » (*ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* ចំណុច ២១.៤.៦ ) ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានថ្លែងថា ៖

« យើងស្រឡាញ់ពួកគេទុកដូច ជាបុត្រាបុត្រីរបស់ព្រះ ។ ពួកគេអាចមានទំនោរការល្បួងជាក់លាក់ ដែលមានអានុភាព ហើយដែលអាចពិបាកនឹងគ្រប់គ្រង ។ មនុស្សភាគច្រើន មានការល្បួងប្រភេទនេះ ឬ ប្រភេទនោះ នៅពេលផ្សេងៗគ្នា ។ ប្រសិនបើពួកគេពុំទោរទន់ទៅតាមការល្បួងនោះទេ ពួកគេអាចឈានឆ្ពោះទៅមុខដូចជាសមាជិកដទៃទៀតក្នុងសាសនាចក្រផងដែរ ។ ប្រសិនបើពួកគេល្មើសច្បាប់ព្រហ្មចារីយភាព និងបទដ្ឋានសីលធម៌របស់សាសនាចក្រ នោះពួកគេស្ថិតនៅក្រោមការដាក់វិន័យរបស់សាសនាចក្រ ដូចជាអ្នកដទៃដែរ » (What Are People Asking about Us ? » សន្និសីទទូទៅ ខែតុលា ឆ្នាំ ១៩៩៨ ) ។

មិនថាមនុស្សម្នាក់នោះមានស្ថានភាពយ៉ាងណាទេ គាត់ ឬនាង អាចរួមចំណែកចំពោះបុព្វហេតុរបស់ព្រះអម្ចាស់នៅក្នុងពេលបច្ចុប្បន្ន ហើយអាចរំពឹងទុកថា ភាពស្មោះត្រង់របស់គាត់ ឬនាងនឹងនាំមកនូវពរជ័យដូចគ្នា ទាំងនៅទីនេះ និងនៅពេលខាងមុខ ដែលព្រះបានសន្យាដល់មនុស្សណាដែលមានភាពស្មោះត្រង់ស្រដៀងគ្នានេះ ។ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន បានសង្កេតមើលថា ៖

« មនុស្សគ្រប់រូបមានអំណោយទាន មនុស្សគ្រប់រូបមានទេពកោសល្យ មនុស្សគ្រប់រូបអាចរួមចំណែកដើម្បីបើកបង្ហាញអំពីផែនការរបស់ព្រះនៅក្នុងជំនាន់នីមួយៗ ។ មានអ្វីជាច្រើនដែលល្អ ហើយសំខាន់-- ទោះពេលខ្លះអ្វីៗទាំងអស់នោះចាំបាច់ក្នុងពេលនេះក្តី--ក៏យ៉ាងហោចណាស់វាអាចសម្រេចបានទោះក្នុងស្ថានភាពមិនសូវល្អក្តី ។ ដូច្នេះបងប្អូនជាច្រើនកំពុងខំអស់ពីសមត្ថភាពហើយ ។ ហើយនៅពេលអ្នករែកបន្ទុកដ៏ធ្ងន់នៃជីវិតរមែងស្លាប់ដោយ

ក្រោកឈរឡើងការពារផែនការរបស់ព្រះ ដើម្បីតម្កើងកូនចៅទ្រង់ នោះយើងទាំងអស់គ្នាត្រៀមខ្លួនដើម្បីគាំទ្រ ។ យើងសូមថ្លែងទីបន្ទាល់ដោយមានទំនុកចិត្តថា ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ បានធ្វើទុកជាមុន ហើយនៅទីបញ្ចប់នឹងសងនូវការខូះខាត និងការបាត់បង់ទាំងអស់ ដល់អ្នកដែលបែរទៅរកទ្រង់ ។ គ្មាននរណាម្នាក់ ត្រូវបានកំណត់វាសនាមកឲ្យទទួលតិចជាង អ្វីៗទាំងអស់ ដែលព្រះវរបិតាមានសម្រាប់កូនចៅរបស់ទ្រង់នោះទេ » ( « Why Marriage, Why Family, » សន្និសីទទូទៅ ខែមេសា ឆ្នាំ ២០១៥ ) ។

## ច្បាប់ព្រហ្មចារីយភាពអនុវត្តចំពោះកូនចៅរបស់ព្រះគ្រប់រូប

ភាពបរិសុទ្ធខាងផ្លូវភេទ គឺជាផ្នែកដ៏សំខាន់មួយនៃផែនការរបស់ព្រះសម្រាប់សុភមង្គលរបស់យើង ។ គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់បានប្រកាសថា ៖

« ព្រះបញ្ញត្តិទីមួយដែលព្រះបានប្រទានដល់លោកអ័ដាម និងនាងអេវ៉ា ទាក់ទងទៅនឹងសមត្ថភាពរបស់ពួកគេសម្រាប់ភាពជាឪពុកម្ដាយ ក្នុងនាមជាស្វាមី និងភរិយា ។ យើងសូមប្រកាសថា ព្រះបញ្ញត្តិរបស់ព្រះសម្រាប់ឲ្យកូនចៅរបស់ទ្រង់បង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដីនេះនៅតែឲ្យប្រតិបត្តិនៅឡើយ ។ យើងក៏សូមប្រកាសផងដែរថា អំណាចដ៏ពិសិដ្ឋនៃការបង្កើតជីវិត គឺត្រូវបានប្រើរវាងបុរស និងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ជាស្វាមីភរិយាប៉ុណ្ណោះ » ( « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ) ។

ទំនាក់ទំនងខាងផ្លូវភេទរវាងបុរសម្នាក់ និងស្ត្រីម្នាក់ដែលពុំបានរៀបការ ឬរវាងមនុស្សដែលមានភេទដូចគ្នា គឺជាអំពើបាប ហើយល្មើសនឹងក្រឹត្យវិន័យដ៏សំខាន់បំផុតមួយរបស់ព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ហើយវារាំងស្ទះដល់ការរីកចម្រើនដ៏អស់កល្បជានិច្ចរបស់យើង ។

« ច្បាប់ព្រហ្មចារីយភាពរបស់ព្រះអម្ចាស់ គឺជាបម្រាមចំពោះទំនាក់ទំនងខាងផ្លូវភេទ នៅក្រៅចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយជាភក្ដីភាពនៅក្នុងអាពាហ៍ពិពាហ៍។ ទំនាក់ទំនងខាងផ្លូវភេទ គឺប្រើបានសម្រាប់តែរវាងបុរសម្នាក់ និងស្ត្រីម្នាក់ដែលបានរៀបអាពាហ៍ពិពាហ៍ស្រប និងពេញច្បាប់ ជាប្ដីប្រពន្ធប៉ុណ្ណោះ ។ អំពើកំផិត អំពើបាបខាងកាមគុណ ទំនាក់ទំនងផ្លូវភេទដូចគ្នា និងការប្រព្រឹត្តមិនបរិសុទ្ធ ផ្ទុយពីលក្ខណៈធម្មជាតិ ហើយមិនស្អាតស្អំដទៃទៀតទាំងអស់ គឺជាអំពើបាប » (*ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* ចំណុច ២១.៤.៥) ។

មនុស្សដែលមានចេតនាខាងផ្លូវភេទណាមួយដែលល្មើសនឹងក្រឹត្យវិន័យនៃព្រហ្មចារីយភាព អាចត្រូវបានផ្សះផ្សាជាមួយនឹងព្រះតាមរយៈការកែប្រែចិត្ត ។

« កុំឲ្យផិតគ្នាឲ្យសោះ ហើយអ្នកណាដែលផិតគ្នា ហើយមិនប្រែចិត្តទេ នោះនឹងត្រូវបណ្ដេញចេញ ។ ប៉ុន្តែអ្នកណាដែលផិតគ្នា ហើយប្រែចិត្តដោយអស់អំពីចិត្ត ហើយបោះបង់ចោលអំពើនោះ ហើយមិនប្រព្រឹត្តទៀតទេ នោះអ្នកត្រូវអភ័យទោសឲ្យ » (គោលលទ្ធិ និងសេចក្ដីសញ្ញា ៤២:២៤-២៥) ។

# សំណួរដែលគេចោទសួរញឹកញាប់

ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១៦

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

---

*ដកស្រង់ចេញមកពី mormonandgay.lds.org។*

**ហេតុអ្វីក៏ប្រើពាក្យ « ការប្រតិព័ទ្ធភេទដូចគ្នា » ដូច្នេះ ? ហេតុអ្វីក៏មិននិយាយថា « ខ្ទើយ » ទៅបានហើយ ?**

ការប្រតិព័ទ្ធភេទដូចគ្នា ( ប.ភ.ដ ) សំដៅទៅលើការប្រតិព័ទ្ធទៅលើមនុស្សម្នាក់ដែលមានភេទដូចគ្នាខាងសតិអារម្មណ៍ ខាងរូបកាយ ខាងមនោសញ្ចេតនា ឬខាងផ្លូវភេទ ។ ប្រសិនបើអ្នកមានការប្រតិព័ទ្ធភេទដូចគ្នា អ្នកអាច ឬមិនអាចជ្រើសរើសប្រើពាក្យជាក់លាក់មួយនៃចេតនាខាងផ្លូវភេទដើម្បីពិពណ៌នាអំពីខ្លួនអ្នក ។ មិនថាដោយរបៀបណាទេ ការប្រតិព័ទ្ធភេទដូចគ្នា គឺជាពាក្យបច្ចេកទេសមួយ ដែលពិពណ៌នាអំពីការជាប់ទាក់ទងនឹងរឿងនោះដោយពុំប្រើពាក្យជាក់លាក់ណាមួយឡើយ ។ គេហទំព័រនេះ ប្រើពាក្យនេះដើម្បីដាក់បញ្ចូលក្រុមមនុស្សដែលពុំពេញចិត្តនឹងការប្រើពាក្យជាក់លាក់ណាមួយ ប៉ុន្តែពុំមែនបដិសេធចោលនូវវត្តមានអត្តសញ្ញាណមនុស្សខ្ទើយប្រុស មនុស្សខ្ទើយស្រី ឬខ្ទើយនោះទេ ។

**ហេតុអ្វីក៏គេហទំព័រនេះមិនពិភាក្សាអំពីបញ្ហាការមិនពេញចិត្តនឹងភេទ ឬបញ្ហាការវះកាត់ប្តូរភេទ ?**

គោលការណ៍ទូទៅជាច្រើនបានចែកចាយនៅលើគេហទំព័រនេះ ( ឧទាហរណ៍ សារៈសំខាន់នៃការរាប់រក និងសណ្តានចិត្តល្អ ) អនុវត្តចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលជាប់ទាក់ទងនឹងការមិនពេញចិត្តនឹងភេទ ឬស្គាល់ថាជាអ្នកវះកាត់ប្តូរភេទ ។ ទោះជាយ៉ាងណាក៏ដោយ ការប្រតិព័ទ្ធភេទដូចគ្នា និងការមិនពេញចិត្តនឹងភេទ គឺមានភាពខុសគ្នាខ្លាំងណាស់ ។ ឧទាហរណ៍ មនុស្សដែលជាប់ទាក់ទងនឹងការមិនពេញចិត្តនឹងភេទ អាចមាន ឬមិនអាចមានការប្រតិព័ទ្ធភេទដូចគ្នាទេ ហើយភាគច្រើនមនុស្សដែលជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នាគ្មានបំណងប្រាថ្នាដើម្បីផ្លាស់ប្តូរភេទរបស់ពួកគេឡើយ ។ នៅក្នុងទស្សនវិស័យខាងចិត្តសាស្រ្ត និងខាងនិតិប្រតិបត្តិ ទស្សនៈទាំងពីរនេះគឺខុសគ្នា ។

**តើអ្នកកំពុងសួរខ្លួនឯងថា អ្នកជាមនុស្សខ្ទើយឬ ?**

ប្រសិនបើអ្នកកំពុងសួរខ្លួនឯងថា តើអ្នកជាមនុស្សខ្ទើយឬ នោះអ្នកប្រហែលជាមានជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា ហើយកំពុងតែងឿងឆ្ងល់ថាតើត្រូវបកស្រាយអំពីអារម្មណ៍ទាំងនេះដោយរបៀបណា ។ បំណងប្រាថ្នាខាងផ្លូវភេទគឺស្មុគស្មាញ ហើយរងឥទ្ធិពលដោយកត្តាជាច្រើន ។ ខណៈដែលការប្រតិព័ទ្ធខាងមនោសញ្ចេតនា ខាងសតិអារម្មណ៍ ឬខាងផ្លូវភេទ អាចបង្ហាញសញ្ញានៃការមានចេតនាខាងផ្លូវភេទ នោះអ្នកមិនគួរសន្និដ្ឋានដោយស្វ័យប្រវត្តិថាវាមាននោះទេ ។ បំណងប្រាថ្នាខាងផ្លូវភេទ អាចប្រែប្រួល ហើយផ្លាស់ប្តូរ ។ ប្រសិនបើអ្នកកំពុងមានចម្ងល់ អ្នកមិនគួរមានអារម្មណ៍រងសម្ពាធ ឬប្រញាប់ឈានទៅដល់ការសន្និដ្ឋានអំពីភេទរបស់អ្នកទេ ។

ពាក្យជាច្រើនមានន័យផ្សេងៗទៅតាមមនុស្សខុសៗគ្នា ហើយនិយមន័យនៃពាក្យមួយអាចផ្លាស់ប្តូរពេញមួយជីវិតរបស់យើង ។ តើពាក្យ *មនុស្សខ្ទើយ* មានន័យយ៉ាងណាចំពោះអ្នក ? តើវាជាអារម្មណ៍មួយឬ ? តើវាជាអត្តសញ្ញាណមួយឬ ? តើវាជាបែបផែនជីវិតមួយឬ ? ការប្រើប្រាស់ពាក្យ *មនុស្សខ្ទើយ* បានផ្លាស់ប្តូរនៅពេលសង្គម និងវប្បធម៌ផ្លាស់ប្តូរ ។ ការស្គាល់ថាជាមនុស្សខ្ទើយ អាចមានន័យថា អ្នកជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា ប៉ុន្តែមិនជ្រើសរើសធ្វើតាមអារម្មណ៍ទាំងនេះទេ ។ ឬប្រហែលជាពាក្យនេះពិពណ៌នាអំពីរបៀបដែលអ្នកបង្ហាញពីខ្លួនអ្នកខាងសតិអារម្មណ៍ ខាងរូបកាយ ខាងផ្លូវភេទ ឬខាងនយោបាយ ។ ប្រសិនបើអ្នកកំពុងតែងឿងឆ្ងល់ថានរណាម្នាក់ចង់មានន័យយ៉ាងណា នៅពេលពួកគេនិយាយថា « ខ្ញុំជាមនុស្សខ្ទើយ » នោះ ចូរសួរពួកគេ ។

**តើខ្ញុំគួរតែប្រាប់គេឬ ?**

សម្រាប់មនុស្សមួយចំនួន ការរក្សាអារម្មណ៍នៃការប្រតិព័ទ្ធភេទដូចគ្នាទុកជាសម្ងាត់ អាចមកពីមានការខ្មាសអៀន ឬការសន្ទនាអវិជ្ជមាននៅខាងក្នុងខ្លួន ។ ការចែកចាយអារម្មណ៍ទាំងនោះជាមួយនឹងមនុស្សម្នាក់ដែលទុកចិត្ត អាចនឹងដោះខ្លួនឲ្យមានសេរីភាព ហើយមានការ

ព្យាបាល ។ ទោះជាយ៉ាងណា មនុស្សមួយចំនួនចង់រង់ចាំឲ្យយូរ ឬយ៉ាងហោចណាស់កំណត់ចំនួនមនុស្សដែលពួកគេប្រាប់ពីអារម្មណ៍ទាំងឡាយ ដូច្នេះ ការសម្រេចចិត្តនេះមិនគួរផ្អែកទៅលើទំនោរសម្ពាធដើម្បី « ប្រកាស » ជាសាធារណៈ ឬប្រាប់គេឲ្យស្គាល់ថាជាមនុស្សខ្ទើយដោយបើកចំហនោះទេ ។ ប្រសិនបើអ្នកសម្រេចចិត្តថាចង់ប្រាប់គេពីអារម្មណ៍ប្រតិព័ទ្ធភេទដូចគ្នា សូមពិចារណាដោយការអធិស្ឋានអំពីមនុស្សដែលអ្នកចង់ប្រាប់រឿងនេះ និងរបៀបដើម្បីចែកចាយទិដ្ឋភាពនៃបទពិសោធន៍ជីវិតរមែងស្លាប់របស់អ្នកនេះ ។

ប្រសិនបើអ្នកសម្រេចចិត្តថាចង់ចែកចាយបទពិសោធន៍របស់អ្នកអំពីអារម្មណ៍នៃការប្រតិព័ទ្ធភេទដូចគ្នា ឬប្រាប់ដោយបើកចំហថាខ្លួនជាមនុស្សខ្ទើយ នោះអ្នកគួរតែទទួលបាននូវការទ្រទ្រង់ និងការរាប់អានដោយសណ្ដានចិត្តល្អ និងការគោរព ទាំងនៅក្នុងផ្ទះ និងនៅព្រះវិហារ ។ យើងទាំងអស់គ្នាចាំបាច់ត្រូវមានការអត់ធ្មត់ចំពោះគ្នាទៅវិញទៅមក នៅពេលយើងដឹងអំពីរឿងទាំងនេះ ។

ក្នុងនាមជាសមាជិកនៃសាសនាចក្រ យើងទាំងអស់គ្នាមានការទទួលខុសត្រូវមួយដើម្បីបង្កើតនូវបរិយាកាសមួយដែលមានការទ្រទ្រង់ និងមានសេចក្ដីស្រឡាញ់ចំពោះបងប្អូនប្រុសស្រីទាំងអស់របស់យើង ។ បណ្ដាញនៃការទ្រទ្រង់គ្នាមួយបែបនេះ ធ្វើឲ្យវាមានការងាយស្រួលកាន់តែច្រើនឡើងនៅក្នុងការរស់នៅតាមដំណឹងល្អ ហើយស្វែងរកព្រះវិញ្ញាណ ខណៈដែលកំពុងឆ្លងកាត់ទិដ្ឋភាពនានានៃជីវិតរមែងស្លាប់នេះ ។

### តើខ្ញុំអាចនិយាយទៅកាន់ឪពុកម្ដាយ ឬប៊ីស្សពខ្ញុំ អំពីការប្រតិព័ទ្ធភេទដូចគ្នាដោយរបៀបណា ?

ប្រសិនបើអ្នកមានអារម្មណ៍ថាអាចនិយាយនឹងឪពុក ឬម្ដាយ សមាជិកគ្រួសារផ្សេងទៀត ឬអ្នកដឹកនាំសាសនាចក្រម្នាក់បាន ចូរពិចារណាចែកចាយអំពីអារម្មណ៍របស់អ្នកជាមួយនឹងពួកគេ ។ សូមជួយពួកគេយល់អំពីអ្វីដែលអ្នកកំពុងឆ្លងកាត់ ដើម្បីពួកគេអាចបង្ហាញសេចក្ដីស្រឡាញ់ និងគាំទ្រ ។ ប្រសិនបើពួកគេពុំយល់អំពីបទពិសោធន៍នេះទេ ចូរសូមពួកគេឲ្យអានអត្ថបទនៅលើគេហទំព័រនេះ ។ រឿងនេះអាចនឹងពុំមែនជាការសន្ទនាដ៏ងាយស្រួលដើម្បីចាប់ផ្ដើមនោះទេ ប៉ុន្តែវាសំខាន់ដើម្បីធ្វើឲ្យមានការសន្ទនាមួយកើតឡើង ។ ចូរមានចិត្តអត់ធ្មត់នឹងមនុស្សនៅជុំវិញអ្នក ហើយចងចាំថាអ្នកទាំងអស់គ្នាកំពុងរៀនជាមួយគ្នា ។ ប្រសិនបើមនុស្សដែលអ្នកស្រឡាញ់ពិបាកយល់ ឬពិបាកជួយគាំទ្រ នោះពួកគេអាចនឹងត្រូវការជំនួយរបស់អ្នក ។ ចូរប្រព្រឹត្តនឹងឪពុកម្ដាយ និងអ្នកដឹកនាំរបស់អ្នកដោយសន្ដានចិត្តល្អ និងការគោរពដូចគ្នា ដូចដែលអ្នកសង្ឃឹមចង់ឲ្យពួកគេធ្វើចំពោះអ្នកដែរនោះ ។ គេហទំព័រនេះ ត្រូវបានរៀបចំឡើងដើម្បីជួយមនុស្សគ្រប់គ្នាឲ្យយល់អំពីការប្រតិព័ទ្ធភេទដូចគ្នាកាន់តែល្អប្រសើរតាមទស្សនវិស័យខាងដំណឹងល្អ ។

### ប្រសិនបើខ្ញុំស្មោះត្រង់ល្មមគ្រប់គ្រាន់ តើការប្រតិព័ទ្ធរបស់ខ្ញុំបែបនេះនឹងរលាយបាត់អស់ទៅដែរឬទេ ?

ប្រពលភាពនៃការប្រតិព័ទ្ធភេទដូចគ្នានេះ គឺពុំវាស់វែងតាមរយៈភាពស្មោះត្រង់របស់អ្នកបាននោះទេ ។ មនុស្សជាច្រើនអធិស្ឋានអស់ជាច្រើនឆ្នាំ ហើយធ្វើអ្វីៗទាំងអស់ដែលពួកគេអាចធ្វើបានដើម្បីមានការគោរពប្រតិបត្តិ ប៉ុន្តែពួកគេនៅតែមានការប្រតិព័ទ្ធភេទដូចគ្នា ។ ការប្រតិព័ទ្ធភេទដូចគ្នា គឺកើតឡើងតាមលំដាប់ផ្សេងៗនៃប្រពលភាព ហើយមិនដូចគ្នាចំពោះមនុស្សគ្រប់រូបនោះទេ ។ មនុស្សមួយចំនួនមានការប្រតិព័ទ្ធមនុស្សទាំងពីរភេទ ហើយមនុស្សផ្សេងទៀតមានការប្រតិព័ទ្ធមនុស្សភេទដូចគ្នាយ៉ាងខ្លាំង ។ ចំពោះមនុស្សខ្លះ អារម្មណ៍នៃការប្រតិព័ទ្ធភេទដូចគ្នា ឬយ៉ាងហោចណាស់ប្រពលភាពនៃអារម្មណ៍ទាំងនេះ អាចនឹងរលាយបាត់ទៅក្នុងមួយរយៈពេល ។ ក្នុងករណីណាក៏ដោយ ការផ្លាស់ប្ដូរនៅក្នុងការប្រតិព័ទ្ធនេះពុំគួររំពឹងទុក ឬតម្រូវឲ្យចេញជាលទ្ធផលមួយមកពីសំណាក់ឪពុកម្ដាយ ឬអ្នកដឹកនាំឡើយ ។

ប្រពលភាពនៃការប្រតិព័ទ្ធរបស់អ្នកអាចនឹងមិនស្ថិតនៅក្នុងការគ្រប់គ្រងរបស់អ្នក តែទោះជាយ៉ាងណា អ្នកអាចជ្រើសរើសរបៀបដើម្បីឆ្លើយតបនឹងវាបាន ។ សូមទូលសួរចំពោះព្រះអម្ចាស់ថាតើអ្នកអាចរៀនអ្វីខ្លះមកពីបទពិសោធន៍នេះ ហើយថាតើបទពិសោធន៍នេះអាចក្លាយទៅជាកម្លាំងមួយដើម្បីអ្នកអាចផ្ដោតសេចក្ដីជំនឿរបស់អ្នកទៅលើលទ្ធផលដែលអ្នកអាចគ្រប់គ្រងបានតាមរបៀបណា ។ ការបង្វែរជីវិតរបស់អ្នកទៅរកព្រះ គឺជាសកម្មភាពនៃសេចក្ដីជំនឿដ៏សំខាន់មួយ ដែលនាំមកនូវពរជ័យដ៏មហិមានាពេលឥឡូវនេះ និងជាពរជ័យកាន់តែមហិមានៅក្នុងបរលោកនាយ ។

### តើសាសនាចក្រនឹងកែប្រែគោលលទ្ធិរបស់ខ្លួន ហើយអនុមតិឲ្យមានអាពាហ៍ពិពាហ៍ភេទដូចគ្នាដែរទេ ?

ផ្នែកសំខាន់ចំពោះផែនការរបស់ព្រះ គោលលទ្ធិនៃអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និងស្ត្រីម្នាក់ គឺជាការបង្រៀនដ៏សំខាន់មួយរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយវានឹងមិនផ្លាស់ប្ដូរឡើយ ៖

« ជាគោលការណ៍មួយខាងគោលលទ្ធិ ផ្អែកទៅលើព្រះគម្ពីរ សាសនាចក្របញ្ជាក់ថា អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺមានសារៈសំខាន់ចំពោះផែនការរបស់អង្គបង្កបង្កើត សម្រាប់ជោគវាសនាដ៏អស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់ ។

« ទំនាក់ទំនងខាងផ្លូវភេទ គឺប្រើបានសម្រាប់តែរវាងបុរសម្នាក់ និងស្ត្រីម្នាក់ដែលបានរៀបអាពាហ៍ពិពាហ៍ស្រប និងពេញច្បាប់ ក្នុងនាមជាប្ដីប្រពន្ធប៉ុណ្ណោះ ។ ទំនាក់ទំនងខាងផ្លូវភេទដទៃទៀត រួមមានទាំងទំនាក់ទំនងខាងផ្លូវភេទរវាងមនុស្សដែលមានភេទដូចគ្នា គឺជាអំពើបាប ហើយបំផ្លាញចោលនូវស្ថាប័នគ្រួសារដែលបានបង្កើតឡើងដ៏ទេវភាព ។ ដូច្នោះសាសនាចក្របញ្ជាក់អំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ថា ជាសម្ព័ន្ធភាពស្របច្បាប់ និងពេញច្បាប់រវាងបុរសម្នាក់ និងស្ត្រីម្នាក់ » (*ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* ចំណុច ២១.៤.១០ ) ។